ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៥ សសរ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈលើកទី២
## ក្រោមប្រធានបទ "TVET អាចធ្វើបាន" ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

-សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
-សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី
-សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗ សិស្ស និស្សិត មាតាបិតា
អាណាព្យាបាល និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!

តាងនាមរាជរដ្ឋាភិបាលនិងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងការចូលរួមអបអរសាទរជាមួយសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មាតាបិតា អាណាព្យាបាល និងបងប្អូនជនរួមជាតិទាំងអស់ ក្នុងឱកាសនៃការប្រារព្ធ **ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ លើកទី២** ក្រោមប្រធានបទ **"TVET អាចធ្វើបាន"** នាថ្ងៃសៅរ៍ ១៣កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩។ ទិវាជាតិដ៏មហោឡារិកនេះ ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងធ្វើការផ្សព្វផ្សាយទៅដល់សិស្សានុសិស្ស យុវជន មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជក និងផ្នែកឯកជន ព្រមទាំងសាធារណជន ឱ្យបានយល់ដឹងអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការអភិវឌ្ឍកម្លាំងពលកម្មជំនាញប្រកបដោយគុណភាពនិងប្រសិទ្ធភាពឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅក្នុង និងក្រៅប្រទេស។

ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដើរតួនាទីដ៏សំខាន់ចាំបាច់ក្នុងការអភិវឌ្ឍមូលធនមនុស្សឱ្យមានចំណេះដឹង សមត្ថភាព ជំនាញ ឥរិយាបថការងារ និងសីលធម៌វិជ្ជាជីវៈដែលជាកត្តាកំណត់ក្នុងការលើកកម្ពស់ផលិតភាព ភាពប្រកួតប្រជែង និងការទាក់ទាញវិនិយោគ សំដៅបន្តរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ បង្កើតការងារថ្មីកាន់តែល្អ ទទួលបានប្រាក់ចំណូលប្រសើរឡើង និងរស់នៅក្នុងភាពសុខដុមរមនា។

បច្ចុប្បន្នកម្ពុជាកំពុងជួបនូវបញ្ហាភាពមិនស៊ីគ្នានៃជំនាញនិងការផ្គត់ផ្គង់ជំនាញមិនគ្រប់គ្រាន់ ដោយសារតែប្រព័ន្ធអប់រំបណ្តុះបណ្តាលនៅមានកម្រិតនិងមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ ជាងនេះទៅទៀត ការវិវត្តបច្ចេកវិទ្យាក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មទី៤ នឹងបណ្តាលឱ្យមានការបាត់បង់ការងារ ហើយក៏បង្កើតឲ្យមានប្រភេទការងារថ្មីៗផងដែរ។ ប៉ុន្តែ អ្នកដែលបាត់បង់ការងារក្នុងដំណាក់កាលវិវត្តនេះ នឹងមិនអាចស្វែងរកការងារបាននោះទេ ប្រសិនបើពួកគេមិនទទួលបានការបណ្តុះបណ្តាលជំនាញឡើងវិញនិងបង្កើនសមត្ថភាពជំនាញ។ ក្នុងន័យនេះ យើងមិនមានជម្រើសអ្វីក្រៅពីបង្កើនសមត្ថភាពជំនាញដល់កម្លាំងពលកម្ម បង្កើនផលិតភាព បង្រួមគម្លាតភាពមិនស៊ីគ្នានៃជំនាញ ពង្រឹងសេវាព័ត៌មានទីផ្សារការងារនិងសេវារកការងារឱ្យធ្វើ បង្កើនគុណភាពអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមា និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលពិភពការងារនិងដើម្បីឆ្លើយតបទៅនឹងតម្រូវការជំនាញនាពេលអនាគត។

ជាមួយគ្នានោះដែរ ដោយបានយល់ឃើញអំពីបញ្ហាប្រឈមខាងលើ និងសក្តានុពលផ្នែកប្រជាសាស្ត្ររបស់កម្ពុជា រាជរដ្ឋាភិបាលនីតិកាលទី៦ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សំដៅធានាកំណើនសេដ្ឋកិច្ចខ្ពស់និងប្រកបដោយចីរភាព តាមរយៈការទាញយកប្រយោជន៍ពីកាលានុវត្តភាពនៅក្នុងតំបន់ ចាប់យកបច្ចេកវិទ្យាថ្មីៗ និងចាប់យកឱកាសក៏ដូចជាជម្នះរាល់ផលអវិជ្ជមាននៃបដិវត្តន៍ឧស្សាហកម្មទី៤ ព្រមទាំងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងគោលដៅឈានទៅសម្រេចបានឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយបានកំណត់ថា **"យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"**។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នេះ ផ្តោតលើអាទិភាពដូចខាងក្រោម៖

- ការអភិវឌ្ឍធនធានមនុស្ស រួមមាន ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និងការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម។

- ការធ្វើពិពិធកម្មសេដ្ឋកិច្ច រួមមាន ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពលនិងឌីជីថល ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ។

- ការអភិវឌ្ឍវិស័យឯកជននិងការងារ រួមមាន ការអភិវឌ្ឍទីផ្សារការងារ ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងឯកជន និងការពង្រឹងការប្រកួតប្រជែង។

ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញជាគោលនយោបាយសំខាន់ៗក្នុងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចខាងក្រោម៖

- គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ សំដៅបង្កើនឱកាសការងារសមរម្យ និងលើកកម្ពស់ផលិតភាពការងារ ជំរុញការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ព្រមទាំង

ពង្រឹងអភិបាលកិច្ចទីផ្សារការងារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការផ្លាស់ប្តូរនៃនិម្មាបនកម្មសេដ្ឋកិច្ច ទាំងក្នុងប្រទេស តំបន់ និងសកលលោក។

- គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ សំដៅលើកកម្ពស់ជីវភាពរស់នៅ សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ បង្កើនបាននូវកម្លាំងពលកម្ម ឬធនធានមនុស្សកម្ពុជាប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត។

ការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការអនុវត្តសម្រេចបានដោយជោគជ័យនូវចក្ខុវិស័យ និងគោលនយោបាយខាងលើ បានបង្ហាញឲ្យឃើញតាមរយៈការកែទម្រង់ជាបន្តបន្ទាប់ និងការបង្កើនថវិកាជាតិសម្រាប់វិនិយោគយ៉ាងច្រើនលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ជាលទ្ធផល យើងបានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលទូទាំងរាជធានី ខេត្ត ដែលផ្តល់ឱកាស និងភាពងាយស្រួលជូនប្រជាពលរដ្ឋគ្រប់រូបក្នុងការទទួលបានជំនាញប្រកបដោយគុណភាពនិងសមធម៌។ ក្នុងរយៈពេល០៥ឆ្នាំចុងក្រោយនេះ មានសិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិតជាង ២០ម៉ឺននាក់ បានទទួលការបណ្តុះបណ្តាលលើកកម្ពស់ជំនាញរបស់ខ្លួន ដើម្បីចាប់យកឱកាសការងារល្អ និងបង្កើតមុខរបរដោយខ្លួនឯង។ ដើម្បីផ្តល់ភាពបត់បែនងាយស្រួលស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ កម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំឱ្យមានជារយៈពេលខ្លីនិងរយៈពេលវែង ក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ហើយត្រូវបានអនុវត្តធ្វើឡើងនៅតាមគ្រឹះស្ថាន សហគ្រាស សហគមន៍ និងចល័ត។ ការបណ្តុះបណ្តាលជំនាញការងារជាក់ស្តែងតាមរយៈការហ្វឹកហ្វឺនកូនជាងនៅតាមសហគ្រាស គ្រឹះស្ថានត្រូវបានអនុវត្ត និងពង្រីកជាបន្តបន្ទាប់ស្របតាមច្បាប់ស្តីពីការងារ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានផ្តល់អាហារូបករណ៍កាន់តែច្រើនជូនដល់យុវជនដែលបោះបង់ចោលការសិក្សា កូនចៅប្រជាពលរដ្ឋក្រីក្រ ស្ត្រី ជនពិការ កុមារកំព្រា ជនជាតិដើមភាគតិច កម្មករ កម្មការិនី ដែលបាត់បង់ការងារនិងជនងាយរងគ្រោះ ដើម្បីមានលទ្ធភាពទទួលបានការបណ្តុះបណ្តាលជំនាញឡើងវិញ និងបង្កើនសមត្ថភាពជំនាញ។ អន្តេវាសិកដ្ឋានសម្រាប់គ្រូ សិក្ខាកាម សិស្ស និស្សិតក្រីក្រ និងស្ត្រីស្នាក់នៅរៀនសូត្រ ត្រូវបានកសាងជាបន្តបន្ទាប់នៅតាមគ្រឹះស្ថានបណ្តុះបណ្តាល។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់អាទិភាពក្នុងការបង្កើន បន្តការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបច្ចេកទេសថ្មីៗជារៀងរាល់ឆ្នាំ។

ទន្ទឹមនឹងការពង្រីកបរិមាណ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើការលើកកម្ពស់គុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការជំនាញ និងការរីកចម្រើនផ្នែកបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស ព្រមទាំងអាចប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់ ដោយពង្រីកការកសាងហេដ្ឋារចនាសម្ព័ន្ធ រោងជាង បន្ទប់ពិសោធន៍ មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ បំពាក់មូលដ្ឋានសម្ភារនិងបរិក្ខារ លើកកម្ពស់គុណភាពសមត្ថភាពគ្រូ ដាក់ឱ្យអនុវត្តស្តង់ដានិងកម្មវិធីសិក្សាថ្មីផ្អែកលើសមត្ថភាព អនុវត្តនូវកម្មវិធីវិញ្ញាបនបត្រវិជ្ជាជីវៈ ដាក់ឱ្យដំណើរការប្រព័ន្ធវាយតម្លៃផ្អែកលើសមត្ថភាពនិងផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ ពង្រឹងទំនាក់ទំនងជាមួយឧស្សាហកម្ម និងការចុះកម្មសិក្សាអនុវត្តផ្ទាល់នៅកន្លែងធ្វើការ ដាក់ឱ្យអនុវត្តប្រព័ន្ធធានាគុណភាព និងពង្រឹងអភិបាលកិច្ចក្នុងវិស័យអប់រំបណ្តុះបណ្តាល

បច្ចេកទេសនិងវិជ្ជាជីវៈ រហូតមកដល់ពេលនេះមានគ្រឹះស្ថានសាធារណៈចំនួន២០ ត្រូវបានទទួលស្គាល់គុណភាពពីអង្គការស្តង់ដាអន្តរជាតិ (ISO)។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនានា ជាពិសេសក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការខិតខំអនុវត្តដោយជោគជ័យនូវការកែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ខ្ញុំព្រះករុណាខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅផងដែរដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មាតាបិតា អាណាព្យាបាល អាជ្ញាធរដែនដី និយោជក ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលបានខិតខំប្រឹងប្រែងចំណាយទាំងកម្លាំងកាយ កម្លាំងចិត្ត និងទាំងធនធានសម្រាប់ជួយជ្រោមជ្រែងដល់ការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជាឲ្យសម្រេចបានជោគជ័យគួរជាទីមោទនៈក្នុងរយៈពេលកន្លងមកនេះ។

ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះ អំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មាតាបិតា អាណាព្យាបាល និយោជក កម្មករនិយោជិត ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបងប្អូនជនរួមជាតិ ដូចតទៅ៖

១.ចូលរួមបន្តថែរក្សាសុខសន្តិភាពនិងស្ថិរភាពនៅកម្ពុជា ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការបន្តការអភិវឌ្ឍមូលធនមនុស្សពោរពេញដោយជំនាញនិងសមត្ថភាព ដើម្បីជំរុញលើកកម្ពស់ផលិតភាព ភាពប្រកួតប្រជែង កំណើនសេដ្ឋកិច្ចខ្ពស់ ការបង្កើតការងារថ្មីកាន់តែល្អ និងរក្សាការងារដែលមានស្រាប់ សំដៅបន្តទៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

២.បន្តចូលរួមនិងផ្តល់ការគាំទ្រក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឈានទៅសម្រេចបានជោគជ័យនូវចក្ខុវិស័យក្នុងការអភិវឌ្ឍធនធានមនុស្សកម្ពុជាប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត។

៣.បន្តលើកទឹកចិត្តនិងបង្កើនការចុះឈ្មោះកូនចៅចូលរៀនជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីមានជំនាញច្បាស់លាស់អាចចាប់យកឱកាសការងារល្អដែលកំពុងរីកចម្រើននិងបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។

៤.គ្រប់ស្ថានីយ៍វិទ្យុនិងទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយនានា សូមបន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីបង្កើនការយល់ដឹងនូវសារៈសំខាន់វិស័យនេះក្នុងចំណោមសាធារណជន។

៥.ដោយឡែកក្នុងឱកាសប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈលើកទី២ ក្រោមប្រធានបទ "**TVET អាចធ្វើបាន**" នេះ សូមក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មាតាបិតា អាណាព្យាបាល និយោជក កម្មករនិយោជិត ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបងប្អូនជនរួមជាតិទាំងអស់ចូលរួមសហការរៀបចំ និងផ្សព្វផ្សាយទិវាជាតិនេះឲ្យបានផុលផុសឱឡារិកអធិកអធមទូទាំងប្រទេស។

ជាទីបញ្ចប់ ជាមួយនឹងឱកាសនៃការប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី២នេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងបងប្អូនជនរួមជាតិទាំងអស់ទូទាំងប្រទេស សូមប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៩ កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**